នស/រកត/០៩០០/១៦០

# ព្រះរាជក្រឹត្យ

## ស្តីពី
## ការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន
## និង សង្គ្រោះជនពិការដោយសារមីន

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧបភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥៩៩/០៣ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការហាមប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦៩៩/១៣៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលខ្លឹមសារនៃ ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១៦ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ១៩៩៥

បានទ្រង់យល់ការក្រាបបង្គំទូលស្នើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ៳៷.

# ត្រាស់បង្គាប់

## ជំពូកទី ១
## នីតិសារជាតិនៃ អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន

មាត្រា ១: ត្រូវបានបង្កើត អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការ ដោយសារមីន ដែលមានអក្សរកាត់ អ.ក.គ.ម.ស.ព.ម. ។ អ.ក.គ.ម.ស.ព.ម. ស្ថិតនៅក្រោមការដឹកនាំផ្ទាល់នៃនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ។

## ជំពូកទី ២
## តួនាទី និង ភារកិច្ច

មាត្រា ២ : អ.ក.គ.ម.ស.ព.ម. មានតួនាទី : គ្រប់គ្រងរាល់សកម្មភាពកំចាត់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលនៅសេសសល់ក្នុងដី និងសង្គ្រោះជនពិការដោយសារគ្រាប់មីន ក្នុងព្រះរាជា ណាចក្រកម្ពុជា ។ អ.ក.គ.ម.ស.ព.ម. ជាស្ថាប័នជាតិតែមួយគត់ តំណាងអោយរាជរដ្ឋាភិបាលកម្ពុជានៅរាល់កិច្ចប្រជុំអន្តរជាតិ ស្តីពីសកម្មភាពមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងសង្គ្រោះជនពិការដោយសារគ្រាប់មីន ។ អ.ក.គ.ម.ស.ព.ម. តំណាងអោយរាជរដ្ឋាភិបាល ចុះហត្ថលេខាលើរាល់កិច្ចព្រមព្រៀង លើពិធីសារ លើកិច្ចសន្យាទាំងឡាយ នៃជំនួយទ្វេភាគី ស្តីពីសកម្មភាពកំចាត់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និង កិច្ចសង្គ្រោះជនពិការដោយសារគ្រាប់មីន ។

មាត្រា ៣ : អ.ក.គ.ម.ស.ព.ម. មានភារកិច្ច ដូចតទៅ :

ក. រៀបចំគោលនយោបាយ ស្តីពីសកម្មភាពកំចាត់មីន និង យុទ្ធភ័ណ្ឌដែលនៅសេសសល់ក្នុងដីមិនទាន់ផ្ទុះ និងសង្គ្រោះជនពិការដោយសារគ្រាប់មីន

ខ. រៀបចំចក្ខុវិស័យជាយុទ្ធសាស្ត្ររយៈពេលមធ្យម និង វែង នៃសកម្មភាពកំចាត់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និង សង្គ្រោះជនពិការដោយសារគ្រាប់មីន ។ល។

គ. រៀបចំផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ នៃសកម្មភាពកំចាត់មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និង សង្គ្រោះជន ពិការ ដោយសារគ្រាប់មីន ក្នុងព្រះរាជាណាចក្រកម្ពុជា

ឃ. សំរបសំរួលនូវរាល់សកម្មភាពកំចាត់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និង សង្គ្រោះជនពិការ ដោយសារគ្រាប់មីន

ង. តាមដាន និងត្រួតពិនិត្យការងារ នៃសកម្មភាពកំចាត់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និង សង្គ្រោះជនពិការដោយសារគ្រាប់មីន ដើម្បីអោយគ្រប់អង្គភាពជាតិ និងអន្តរជាតិប្រតិ-បត្តិករនានា អនុវត្តស្របតាមយុទ្ធសាស្ត្រ និង ផែនការ របស់រាជរដ្ឋាភិបាល

ច. គៀងគរប្រភពធនធាន ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុង និង ក្រៅប្រទេស

ឆ. បញ្ជាអោយកំទេចចោលគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលនៅមាន និងរកឃើញ

ជ. ចេញបទបញ្ញត្តិទាំងឡាយ ដែលទាក់ទងនឹងការអនុវត្តសកម្មភាពប្រឆាំង និងកំចាត់មីន

ឈ. ផ្តល់អាជ្ញាប័ណ្ណដល់រាល់អង្គភាពកំចាត់មីនជាតិ និងអន្តរជាតិនានា ដែលធ្វើសកម្មភាព បោសសំអាតមីន ក្នុងព្រះរាជាណាចក្រកម្ពុជា

ញ. មានសិទ្ធិដកហូតអាជ្ញាប័ណ្ណ ពីអង្គភាពកំចាត់មីនជាតិ និងអន្តរជាតិនានា ដែលធ្វើ សកម្មភាពបោសសំអាតមីន ក្នុងព្រះរាជាណាចក្រកម្ពុជា

ដ. គ្រប់គ្រងទិន្នន័យ និងបណ្ណាល័យសំរាប់ដំកល់ឯកសារដែលទាក់ទងនឹងបញ្ហាមីន និងយុទ្ធ ភ័ណ្ឌមិនទាន់ផ្ទុះ និងកិច្ចសង្គ្រោះជនពិការដោយសារគ្រាប់មីន

ឋ. រៀបចំគោលនយោបាយ ស្តីពីការប្រើប្រាស់ដីធ្លី ដែលត្រូវបានបោសសំអាតមីនរួចហើយ និងត្រួតពិនិត្យការអនុវត្តន៍គោលនយោបាយនេះ

ឌ. គ្រប់គ្រងការអនុវត្តន៍ នូវច្បាប់ស្តីពីការហាមប្រាម ការប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទ ប្រឆាំងមនុស្ស និងអនុសញ្ញាអូតាវ៉ា ស្តីពីការហាមប្រាមការប្រើប្រាស់ រក្សាទុក ផលិត និង ការផ្ទេរមីនប្រឆាំងមនុស្ស ហើយនិងការបំផ្លាញមីនទាំងនោះចោល

ឍ. តាមដាន ពិនិត្យ និងផ្តល់ការណែនាំ ក្នុងការប្រើប្រាស់ថវិកា និង សម្ភារៈបរិក្ខារ ដែល ផ្តល់ដោយជំនួយរាជរដ្ឋាភិបាល និងសហគមន៍អន្តរជាតិ នៃបណ្តាអង្គភាព បោសសំអាត មីនជាតិ និងអន្តរជាតិទាំងអស់ ដែលមានសកម្មភាព ក្នុងព្រះរាជាណាចក្រកម្ពុជា ។ល។

## ជំពូកទី ៣
## រចនាសម្ព័ន្ធគ្រប់គ្រង

មាត្រា ៤ : អ.ក.គ.ម.ស.ព.ម. មានសមាសភាព ដូចតទៅ:

| | |
|---|---|
| - នាយករដ្ឋមន្ត្រី | ជាប្រធាន |
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធាន |
| - ឥស្សរជនជាន់ខ្ពស់ ១ រូប | ជាអគ្គលេខាធិការ |
| - តំណាងក្រសួងការបរទេស | ជាសមាជិក |
| - តំណាងក្រសួងមហាផ្ទៃ | ជាសមាជិក |
| - តំណាងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនិតិសម្បទា | ជាសមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| - តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិក |
| - តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| - តំណាងក្រុមប្រឹក្សារំសាយកងកម្លាំងប្រដាប់អាវុធ | ជាសមាជិក |
| - ឥស្សរជនជាន់ខ្ពស់ជំនាញច្បាប់ ១ រូប | ជាសមាជិក |

មាត្រា ៥ : ក្រៅពី ប្រធាន និង អនុប្រធាន សមាសភាព អ.ក.គ.ម.ស.ព.ម. ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ទៅតាមករណីយសមាជិកម្នាក់ៗ តាមការស្នើសុំរបស់នាយករដ្ឋមន្ត្រី ។ អណត្តិរបស់សមាជិក អ.ក.គ.ម.ស.ព.ម. រយៈពេល ៥ ឆ្នាំ ។ នាយករដ្ឋមន្ត្រីអាចស្នើសុំការតែងតាំងសមាភាពសមាជិកបន្តទៀតបាន ។

មាត្រា ៦ : អ.ក.គ.ម.ស.ព.ម. មានភារកិច្ច គ្រប់គ្រង អនុមត័សំរេច លើរាល់គំរោងផែនការ និងសកម្មភាពនានា ដើម្បីបានានូវប្រសិទ្ធភាព និងតម្លាភាព ក្នុងការអនុវត្តន៍នូវរាល់ភារកិច្ចដូចមានចែងក្នុងមាត្រា ២ នៃព្រះរាជក្រឹត្យនេះ ។ល។

មាត្រា ៧ : អ.ក.គ.ម.ស.ព.ម. រួមប្រជុំ ៣ ខែម្តង តាមការកោះអញ្ជើញ របស់ប្រធាន ដែលជាអ្នកកំណត់របៀបវារៈ ។ តាមការប្រគល់សិទ្ធិរបស់ប្រធាន អនុប្រធានអាចកោះប្រជុំ និងកំណត់របៀបវារៈនៃសម័យប្រជុំ អ.ក.គ.ម.ស.ព.ម.។

មាត្រា ៨ : អ.ក.គ.ម.ស.ព.ម. មានគណៈអចិន្ត្រៃយ៍មួយ ដែលមានសមាសភាព ប្រធាន អនុប្រធាន និង អគ្គលេខាធិការ និងដែលមានសិទ្ធិអនុម័តសំរេចលើរាល់ករណី ។

មាត្រា ៩ : អគ្គលេខាធិការ អ.ក.គ.ម.ស.ព.ម. មានភារកិច្ចដឹកនាំ និង បំពេញការងារ អ.ក.គ.ម.ស.ព.ម. ប្រចាំថ្ងៃអោយមានប្រសិទ្ធភាព ។ អគ្គលេខាធិការ អ.ក.គ.ម.ស.ព.ម. ត្រូវតែងតាំងដោយព្រះរាជក្រឹត្យសំរាប់រយៈ ពេល ៥ ឆ្នាំ រួចអាចបន្តទៀតបាន ដោយមានការស្នើពីនាយករដ្ឋមន្ត្រី ។

មាត្រា ១០ : នាយករដ្ឋមន្ត្រីអាចតែងតាំងអគ្គលេខាធិការរងពីររូប ជាជំនួយការអគ្គលេខាធិការ : មួយរូបទទួលបន្ទុកកិច្ចការសកម្មភាពកំចាត់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងមួយរូបទៀតទទួលបន្ទុកកិច្ចការសង្គ្រោះជនពិការដោយសារមីន ។ អគ្គលេខាធិការរង ត្រូវតែងតាំងដោយអនុក្រឹត្យ ។

មាត្រា ១១: អ.ក.គ.ម.ស.ព.ម. មានអគ្គលេខាធិការដ្ឋានមួយ និងអង្គភាពមួយចំនួនទៀត តាមការចាំបាច់នៃការបំពេញការងារទូទៅរបស់ អ.ក.គ.ម.ស.ព.ម.។

មាត្រា ១២: ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និង ភារកិច្ចលំអិតទូទៅរបស់ អ.ក.គ.ម.ស.ព.ម. និង អគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយឡែក ដោយអនុក្រឹត្យ ។

មាត្រា ១៣ : អ.ក.គ.ម.ស.ព.ម. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ១៤ : ដើម្បីដំណើរការសកម្មភាពរបស់ខ្លួន អ.ក.គ.ម.ស.ព.ម. ត្រូវមានខ្ទង់ថវិកាមួយ ដែលភ្ជាប់ជាមួយថវិកានៃទីស្តីការគណៈរដ្ឋមន្ត្រី ។ល។

## ជំពូកទី ៤

## ប្រភពធនធាន

មាត្រា ១៥ : ប្រភពធនធាន អ.ក.គ.ម.ស.ព.ម. ត្រូវបានមកពី :

- ថវិការាជរដ្ឋាភិបាលកម្ពុជា
- ជំនួយពីសហគមន៍អន្តរជាតិ និង អង្គការផ្តល់ជំនួយនានា
- ប្រាក់កម្រៃបានមកពីសេវាកម្មផ្សេងៗ ផ្តល់ដោយអង្គការសាធារណៈ ឬ ឯកជន ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

មាត្រា ១៦ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៧ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ។

មាត្រា ១៨ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។ល។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

លេខ :១៧៧ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០០០

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់